# ការពិតលើអ្វីដែលគេហៅថា "រដ្ឋប្រហារ" ថ្ងៃទី១៨ ខែមិនា ១៩៧០នៅភ្នំពេញ

ដោយ ចៅ-សេងអួរ

រហូតមកដល់សព្វថ្ងៃ អ្នកកាសែតបស្ចឹមប្រទេស និងអ្នកកាសែតខ្មែរផងដែរហើយនិងអ្នកនិពន្ធសៀវភៅស្ដីពីប្រទេសកម្ពុជា ក្នុងរបបខ្មែរក្រហមបន្ដជំនឿថា ការទម្លាក់សម្ដេចសីហនុពីតំណែងប្រមុខរដ្ឋដោយស្របតាមច្បាប់រដ្ឋធម្មនុញ្ញនោះ គឺជា«រដ្ឋប្រហារ»ទៅវិញ ( សៀវភៅលោករិទ្ធី-បាញ់ និងអ្នកស្រីគ្រីស្ទីន-ស្ហាម៉ូ Christine Chameau មានឈ្មោះថា ៖ «ម៉ាស៊ីនខ្មែរក្រហម ៖ មន្ទីរសន្តិសុខស-២១» បោះពុម្ពផ្សាយដោយ Flammarion ខែមិនា ឆ្នាំ២០០៣ ។ នៅទំព័រទី១៩ គេសរសេរថា ៖ ១៩៧០-រដ្ឋប្រហាររបស់សេនាប្រមុខលន់-នល់ រំលំសម្ដេចនរោត្ដម សីហនុ និងសង្គ្រាមស៊ីវិលរវាងខ្មែរគ្នាឯងក្នុងស្រុក» ) ។

ការពិតលោកសេនាប្រមុខលន់-នល់ឥតបានធ្វើរដ្ឋប្រហារទៅលើសម្ដេចនរោត្ដម-សីហនុទេ ។ ដោយហេតុថា សម្ដេចនរោត្ដម-សីហនុនៅពេលនោះ បានត្រូវរដ្ឋសភានិងក្រុមប្រឹក្សាព្រះរាជាណាចក្រ បានបោះឆ្នោតដកសេចក្ដីទុកចិត្តពី លោកចំនួន<៩២សម្លេងយល់ព្រម> ឥតមានសម្លេងប្រឆាំងឬអនុប្បវាទទេ ។ គឺជា វិធីដោះស្រាយបញ្ចប់នូវវិបត្តិនយោបាយមួយ ដែលសម្ដេចសីហនុលោកបានធ្វើឲ្យស្មុះដោះស្រាយមិនចេញ ។

នៅដើមឆ្នាំ១៩៧០, នៅភ្នំពេញ, ឥតមាននរណាម្នាក់មានបំណងដកសម្ដេចសីហនុចេញពីអំណាចនោះទេ ។ សម្ដេចទេដែលងាកចេញពីអំណាច ដោយចាកចេញពីស្រុកនៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧០ គ្មានកំណត់ថាពេលណានឹងត្រឡប់ចូលស្រុកវិញ ។ សម្ដេចថាទៅព្យាបាលរោគនៅស្រុកបារាំង ដោយអះអាងថាមានជម្ងឺ ប៉ុន្តែការពិតសម្ដេចគ្មានឈឺអ្វីសោះ ។

នៅថ្ងៃនោះពេលប្រហែលម៉ោង៧យប់ សឹងតែគ្មាននរណាម្នាក់បានដឹងថា ប្រមុខរដ្ឋចាកចេញពីប្រទេសទៅបរទេសឡើយ ។ ទ្រង់សិរិមតៈលោកបានបញ្ជារឲ្យខ្ញុំទៅជួបលោក នៅអាកាសយានដ្ឋានពោធិចិនតុង ។ ពេលនោះ ខ្ញុំបានឃើញសមាជិករាជរដ្ឋាភិបាល២រូបទៀតឈរនៅជិតទ្រង់សិរិមតៈគឺ លោកឧប-គីនអាង និងទ្រិញ-វ៉ាញ ។ សម្ដេចយាងមកដល់ ជាមួយភរិយា និងក្រុមអ្នកជិតស្និទ្ធមួយចំនួនតូច ។ សម្ដេចបានយាងឡើងយន្តហោះ ធ្វើសញ្ញាលាពីចម្ងាយទៅលើមនុស្សនៅទីនោះទាំងអស់ ។ ការចេញដំណើរដោយគ្មានគ្រោងទុកមុននេះ ប្រៀបបានដូចការគេចរត់ចោលយករួចខ្លួននៅចំពោះនៃការទទួលខុសត្រូវ ដែលសម្ដេចមិនចង់ទទួលបន្ទុកខ្លួនឯងនៅក្នុងកាលៈទេសៈមិនល្អ ស្ថានភាពលំបាកខ្លាំងក្នុងប្រទេស ។ ពេលនោះស្ថានភាពប្រទេសអាក្រក់ណាស់ ៖ សេដ្ឋកិច្ចរឃីករយាកខ្លាំង បូកជាមួយការព្រួយបារម្ភជាខ្លាំងបណ្ដាលមកពីកំណែនដ៏ធំធេងនៃការជ្រៀតជ្រែកចូលយ៉ាងសម្ងាត់ពីទ័ពកុម្មុយនិស្តយួនមកក្នុងដែនដីខ្មែរ ។

ការចាកចេញទៅបរទេស និងការពន្យាអវត្តមានដ៏វែងគ្មានដំណឹងថា ពេលណាត្រូវត្រឡប់ចូលស្រុកវិញនោះ បណ្ដាលឲ្យ «រាជរដ្ឋាភិបាលជាតិ ដែលសម្ដេចខ្លួនឯងបានតែងតាំងពីថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៦៩»នោះ ត្រូវប្រឈមនៅចំពោះមុខបញ្ហាជាច្រើន ។ បញ្ហាដែលពិបាកដោះស្រាយ គឺអាកប្បកិរិយាដែលកងទ័ពកុម្មុយនិស្តយួនសំរេចរក្សាទុកនិងពង្រឹងថែមទៀតនូវជំរករបស់គេនៅក្នុងប្រទេសយើង ។ ចរិករបស់ទ័ពយួនកុម្មុយនិស្តរបៀបនេះ ធ្វើឲ្យមតិខ្មែរទាំងអស់ជាពិសេសយុវជនក្មេងៗពិបាកអត់ឱនឲ្យបាន ។

នៅដើមខែមិនា គឺថ្ងៃទី៨ មិនា ឆ្នាំ១៩៧០, ឧប្បត្តិហេតុដ៏ធ្ងន់ធ្ងរជាច្រើនបានកើតមានឡើង រវាងរាស្ត្រខ្មែរនិងទ័ពយួនកុម្មុយនិស្តនៅខេត្តស្វាយរៀង ។ បីថ្ងៃក្រោយមកទៀត គឺនៅថ្ងៃ១១ មិនា ឆ្នាំ១៩៧០ មានបាតុកម្មប្រឆាំងនឹងយួនយៀកកុង និងហាណូយនៅភ្នំពេញ រាលដាលឲ្យមានការវាយបំផ្លាញស្ថានទូតយួនទាំងពីរ ។ មួយថ្ងៃក្រោយមកទៀត គឺនៅថ្ងៃ១២ មិនា រាជរដ្ឋាភិបាលស្រោចស្រង់ជាតិដែលទទួលការគាបសង្កត់យ៉ាងខ្លាំងពីមតិសាធារណៈ បានសុំឲ្យយួនហាណូយនិងយួនយៀកកុងដកទ័ពរបស់ខ្លួនទាំងអស់ដែលជ្រៀតជ្រែកចូលក្នុងទឹកដីខ្មែរ ឲ្យចេញផុតឲ្យអស់ពីដែនដីខ្មែរនៅថ្ងៃ១៥ មិនា ១៩៧០ ។ នៅថ្ងៃដដែល សម្ដេចសីហនុបានធ្វើកំហុសនយោបាយនិងចិត្តសាស្ត្រយ៉ាងទម្ងន់មួយ ដោយបានផ្ញើទូរលេខ១ច្បាប់ថ្វាយដល់ព្រះមហាក្សត្រីយានី បន្ទោសយ៉ាងខ្លាំងទៅលើបាតុកម្មប្រឆាំងនឹងយួនកុម្មុយនិស្ត ។

ដោយជឿជាក់ថា សម្ដេចដែលគង់នៅប៉ារីសមិនអាចប្រមាណដោយត្រឹមត្រូវបាននូវស្ថានការណ៍នៅក្នុងស្រុក រាជរដ្ឋាភិបាលក៏សំរេចនៅថ្ងៃទី១៣ មិនា ១៩៧០ បញ្ជូនបេសកជនពីររូបគឺ ទ្រង់កន្តុលនិងលោកយែម-សំបួរ ដែលមានឋានៈជារដ្ឋមន្ត្រីក្រសួងការបរទេស ដើម្បីនឹងបំភ្លឺសម្ដេចនៅលើព្រឹត្តិការណ៍ដែលបានកើតឡើងនៅថ្ងៃទី៨ មិនា ឆ្នាំ១៩៧០នោះ ។ រូបខ្ញុំបានទាំងនៅក្នុងអង្គប្រជុំគណរដ្ឋមន្ត្រីនោះដែរ ពេលសំរេចបញ្ជូនឥស្សរជនទាំងពីររូបនោះទៅកាន់ក្រុងប៉ារីសផង ។

ដូច្នេះជាការបង្ហាញថា រាជរដ្ឋាភិបាលគ្មានបំណងណាមួយចង់ទម្លាក់ប្រមុខរដ្ឋនោះទេ ហើយផ្ទុយទៅវិញមានប្រាថ្នាឲ្យសម្ដេចយាងត្រឡប់មកវិញយ៉ាងប្រញាប់ ។ ប៉ុន្តែសម្ដេចសីហនុបានឲ្យដំណឹងថា លោកមិនទទួលបេសកជនទាំង២រូបរបស់រាជរដ្ឋាភិបាលនោះទេ ។ ដោយហេតុនេះហើយបានជាស្ថានភាពប្រទេសត្រូវជួបប្រទះនូវលារស្មុះគឿងថ្កល់ ។ ប៉ុន្តែការរៀបចំប្រុងប្រៀបនៅតែត្រូវធ្វើឡើង ដើម្បីចាំទទួលការវិលចូលស្រុកវិញនៃសម្ដេច នៅអាកាសយានពោធិចិនតុងដដែល ។ ម៉្យាងទៀតមានវរជនដ៏ច្រើនបានទូរស័ព្ទទៅប៉ារីស ទៅកន្លែងដែលសម្ដេចគង់នៅដើម្បីសុំយាងលោកដោយទទូចចចេសឲ្យត្រឡប់ចូលជាប្រញាប់មកភ្នំពេញវិញបើអា ចធ្វើបាន ។

ដោយឃើញមានភាពមិនប្រាកដសោះនៃបំណងរបស់សម្ដេចថាត្រូវចូលស្រុកឬមិនចូលវិញនោះ រាជរដ្ឋាភិបាលមានបំណងពីរយ៉ាង ៖ ទីមួយ គឺដោះស្រាយបញ្ហានៃការចូលច្រើនឡើងៗ ហើយកាន់តែសំខាន់ឡើងៗនៃកងទ័ពកុម្មុយនិស្តយួន ។ ទីពីរ គឺចាប់ផ្ដើមធ្វើការចរចាជាមួយតំណាងយៀកកុងនិងហាណូយនៅភ្នំពេញ ។ ការចរចារវាងខ្មែរ-យួនបានចាប់ផ្ដើមឡើងនៅថ្ងៃទី១៦ មិនា ឆ្នាំ១៩៧០ ក៏ប៉ុន្តែមិនបានផលអ្វីសោះទេ ។

ស្ថានភាពខាងក្រៅ កុម្មុយនិស្តយួនរង់ចាំតែដំណឹងថា តើសម្តេចសីហនុត្រឡប់មកភ្នំពេញឬយ៉ាងណា ? ផ្ទុយពីការសំរេចត្រឡប់មកភ្នំពេញវិញ សម្តេចបែរជាធ្វើដំណើរទៅប៉េកាំងទៅវិញ ។ ដូច្នេះរាជរដ្ឋាភិបាលនៅឯកឯង វិវក់អំពល់ជាមួយកុម្មុយនិស្តយួន ដោយគ្មានបានទទួលបញ្ជាអ្វីបន្តិច សោះពីសម្តេច ស្តីពីវិធានការណ៍ឬអាកប្បកិរិយា ដែលត្រូវប្រកាន់យកទៅលើពួកយួនទាំងនោះ ។ ភាពតានតឹងបែបវិបត្តិនយោបាយរវាងសីហនុ និងរាជរដ្ឋាភិបាលគ្មានច្រកចេញរួច តាមការសំរុះសំរួលទេ ។ ដើម្បីឈានមុខទៅលើ គ្រោះថ្នាក់ដល់ស្លាប់របស់ស្រុកខ្មែរ គេត្រូវតែបញ្ចប់សកម្មភាពស្ទះអត់ច្រកចេញនេះឲ្យបាន ។ ទើបរដ្ឋសភានិងក្រុមប្រឹក្សា ព្រះរាជាណាចក្រសំរេចប្រជុំគ្នានៅថ្ងៃ១៨ មិនា ឆ្នាំ១៩៧០នៅ រដ្ឋសភាសំរេចដកសេចក្តីទុកចិត្តពីប្រមុខរដ្ឋហើយ និងតំរូវដកសម្តេចចេញពីតំណែងស្របតាមរដ្ឋធម្មនុញ្ញជាធរមានក្នុងពេលនោះ ។ ដំណែងប្រមុខរដ្ឋក៏ត្រូវផ្ទេរភ្លាមទៅជូនប្រធានរដ្ឋសភាលោកចេង-ហេង ។ ដូច្នេះសភាការណ៍ដែលកើតមាននៅក្រោមរដ្ឋធម្មនុញ្ញនោះ គ្មានការអ្វីទាក់ទងជាមួយរឿងរដ្ឋប្រហារនោះទេ ។ ស្ថានភាពនេះគឺជាព្រិត្តិការណ៍ដើម្បីបញ្ចប់ ក្នុងសន្តិភាពនៃវិបត្តិនយោបាយដែលបង្កហេតុដោយសម្តេចសីហនុខ្លួនឯង ។

ការដែលគេយកមកនិយាយថាជារដ្ឋប្រហារ ថាជាការធ្វើអន្តរាគមន៍ជាពិសេសពីសំណាក់សេអ៊ីអា CIA គឺជាការភរភូត គួរឲ្យអស់សំណើច ។ ជាការអះអាងខ្វះមូលដ្ឋាន ។ សហរដ្ឋអាមេរិកគ្មានប្រយោជន៍អ្វី មកជ្រៀតជ្រែកក្នុងរឿងខ្មែរទេ ព្រោះពេលនោះការទាក់ទងផ្លូវទូតរវាងវ៉ាស៊ិនតោនជាមួយភ្នំពេញ ត្រូវសម្តេចសីហនុផ្តាច់តាំងពីថ្ងៃ៣ ឧសភា ឆ្នាំ១៩៦៥មក ។ ទំនាក់ទំនងឡើងវិញទើបតែបានចាប់ផ្តើមឡើងវិញ ដែលមានតែភារៈ-ធារីម្នាក់នេះ បិតនៅស្ងៀមស្ងាត់ ហើយគ្មានបានបង្ហាញឬបញ្ចេញវត្តមានទេ ។

ដោយសង្ខេបទៅ គ្មានរដ្ឋប្រហារណាមួយទេ ។ សម្តេចសីហនុអាចជៀសវាងការទំលាក់ពីតំណែងនេះបាន បើប្រសិនជាលោកកុំបង្កើតឬធ្វើឲ្យស្ថានភាពស្ទះគ្មានច្រកចេញនៅពេលនោះ ។ គឺសម្តេចគ្រាន់តែត្រឡប់ចូលភ្នំពេញឲ្យត្រូវទាន់តាមកាលៈទេសៈ ព្រោះរាជរដ្ឋាភិបាលនៅភ្នំពេញនៅរង់ចាំព្រះអង្គដើម្បីមកដោះស្រាយបញ្ហាដ៏ធ្ងន់ធ្ងរនិងប្រកបដោយ គ្រោះថ្នាក់ដែលបង្កើតឡើងដោយការចូលមកតាំងនៅដែលមិនអាចទទួលបាននៃទ័ពកុម្មុយនិស្តយួនខាងជើងយ៉ាងសន្ធឹកសន្ធាប់នៅលើទឹកដីខ្មែរ ។៚

# La Vérité sur le Prétendu « Coup d'Etat » du 18 Mars 1970 à Phnom Penh

Des journalistes occidentaux et aussi khmers, ainsi que (les auteurs de livres traitant du Cambodge des Khmers rouges ont continué de qualifier la destitution légale du Prince Sihanouk du poste de Chef de l'État de «Coup-d'Etat» (Livre de Ritby Panh avec Christine CHAMEAUX intitulé - « La machine khmère rouge: Monti Santesok S-21 » édité par Flammarion en mars 2003, **à la page 19** on lit 1970 :

« Coup d'Etat de Lon Nol qui renversa le Pnince Norodom Sihanouk et guerre civile» **Or il n'y a jamais eu le «coup l'état » du Maréchal Lon Nol contre le Prince Norodom Sihanouk**, mais celui-ci a été destitué de ses fonctions de Chef de l'Etat par un vote unanime ( 92 vois pour, 0 contre et 0 abstention ) du Parlement cambodgien (l'assemblée Nationale et Conseil du Royaume ) comme le dénouement une crise politique que Sihanouk avait lui-même rendu insoluble.

Au début de l'année 1970, personne à Phnom Peuh ne songeait à écarter le Prince Sihanouk du pouvoir. C'est plutôt lui qui s'en est écarté en quittant son pays le 6 Janvier 1970 pour une durée indéterminée soi-disant pour aller se faire soigner en France, alors qu'en réalité, il n'était pas du tout malade. Ce jour-là, vers 19 heures, presque personne n'était au courant dut départ du Chef de l'Etat pour l'étranger. Le Prince Sirik Matak m'avait demandé de le rejoindre à l'aéroport de Pochentong. J'avais vu, debout à côté de Sîrik Matak deux autres membres du Gouvernement, M. Op Kim, Ang et Trinh Hoanh. Le prince arrive accompagné de son épouse et d'un petit nombre de membres de son entourage. Il monta dans l'avion faisant un signe d'au revoir de loin aux personnes présentes. **Son départ inattendu avait alors ressemblé à une fuite devant des responsabilités** qu'il ne voulait pas assumer, le pays étant dans une conjoncture très difficile: situation économique franchement mauvaise et graves inquiétudes causées par l'accroissement important des infiltrations des Vietcong/NVN en territoire khmer.

L'absence du Prince Sihanouk se prolongeant, sans aucune indication quant à son retour, le « gouvernement de sauvetage » mis- en place par Sihanouk le 14 Août 1969, devait faire face à de nombreux problèmes. Le plus difficile à résoudre étant celui posé par l'attitude des forces communistes vietnamiennes, bien décidées à conserver et étendre leurs «sanctuaires», dans le pays. Cette attitude étant de plus en plus mal tolérée par l'opinion publique cambodgienne et en particulier par la jeunesse,

Au début du mois de Mars (le 8 Mars 1970). des incidents sérieux se produisirent dans la province de Svay Rieng entre la population et les forces communistes vietnamiennes. Trois jours plus tard (11 Mars) des manifestation Anti-vietcong et anti-Hanoi eurent lieu à Phnom Penh aboutissant à la mise à sac des deux Ambassades des communistes vietnamiens.

Le jour suivant (12 Mars) le «Gouvernement de Sauvetage », soumis à une forte pression de son opinion publique, demanda à Hanoi et au VC de retirer pour la date du 15 Mars toutes leurs forces infiltré en territoire cambodgien. Le même jour, Sihanouk commentait t une lourde faute, politique et psychologique, en. blâmant très durement les manifestations anti- VC/NVN dans un télégramme adressé à la reine-mère

Persuadé que le Prince qui séjournait alors à Paris ne pouvait pas évaluer correctement la situation le Gouvernement décida le 13 Mars de lui envoyer deux émissaires (le prince Norodom Kantol et M.Yem Sambaur, Ministre des Affaires Etrangères) pour l'éclairer sur les évènements qui venaient d'avoir lieu le 8 Mars 1970. J'étais présent à la séance du Conseil des Ministres qui décida d'envoyer ces deux personnalités à Paris,

Par là même, le Gouvernement montrait clairement qu'il n'envisageait nullement de déposer le Chef de l'Etat, et qu'il souhaitait au contraire son retour rapide à Phnom Penh. Mais Sihanouk fit savoir qu'il ne recevrait pas les deux émissaires du Gouvernement. Ainsi de son fait, la situation se trouvait bloquée Pourtant des préparatifs étaient faits pour l'accueillir à l'aéroport de Pochentong. En outre de nombreuses personnalités avaient téléphoné à Paris où Sihanouk se trouvait alors, pour lui demander avec insistance de regagner le plus tôt possible Phnom Penh.

Dans l'incertitude complète quant aux intentions du Prince concernant son éventuel retour, le Gouvernement, pour tenter d'une part de résoudre le problème **des infiltrations de plus en plus importantes des forces VC/NVN et, d'autre part, d'entreprendre une négociation avec les Représentants du Vietcong et Je Hanoi à Phnom Penh**. Des entretiens khméro-vietnamiens eurent lieu ainsi le 16 Mars mais n'aboutirent à aucun résultat. Apparemment, les communistes vietnamiens attendaient eux aussi de savoir si le Prince allait regagner Phnom Penh. Mais au lieu de reprendre le chemin du retour au pays, Sihanouk quittait Paris pour se rendre à Pékin. **Il laissait ainsi le «Gouvernement de Sauvetage » seul aux prises avec les communistes vietnamiens, sans aucune instruction de sa part quant à la conduite à tenir envers ceux-ci**. La crise politique Sihanouk- Gouvernement était donc devenue sans issue possible à l'amiable. Pour faire face au danger mortel pour le pays, il fallait mettre un terme à cette situation. Les deux Chambres du Parlement khmer se réunirent en Congrès le 18 Mars à l'Assemblée Nationale et décidèrent de retirer leur confiance du Chef de l'Etat et par vole de conséquence, de le destituer de ses fonctions conformément à la Constitution en vigueur à cette époque. Les fonctions de Chef de L'Etat furent aussitôt dévolues in Président Je l'Assemblée Nationale, M. Cheng Heng

Cette situation constitutionnelle n'avait évidemment aucun rapport avec un « Coup l'Etat» Elle apportait seulement un dénouement pacifique à Une crise politique provoquée par Sihanouk lui-même. La journée du 18 mars 1970 fut d'ailleurs très calme à Phnom Penh, où n'eurent lieu aucun incident ni aucune effusion de sang. **La destitution du Prince Sihanouk** fut donc, en définitive, une affaire intérieure purement khmère sans aucune ingérence étrangère. Les allégations attribuant ce soi-disant « "Coup-d'Etat" » à une intervention américaine et, en particulier, à la CIA sont aussi grotesques que mensongères; elles ne reposent sur aucun fondement. Les Etats-Unis d'Amérique n'avaient du reste, aucun intérêt à s'ingérer dans les affaires cambodgiennes, alors que les relations diplomatiques entre Washington le Phnom-Penh. rompues par Sihanouk le 3 Mai 1965, venaient d'être rétablies depuis quelques mois seulement, le 2 juillet 1969. La Représentation américaine à Phnom-Penh, qui n'avait à sa tête qu'un Chargé d'affaires se montrait donc discret et prenait grand soin de garder un « profil bas ».

En résumé, il n'y eut aucun « coup d'Etat » et Sihanouk aurait très bien pu éviter sa destitution en ne créant pas lui-même une situation bloquée sans issue. Il lui suffisait de revenir en temps opportun à Phnom-Penh, où son retour était attendu par le Gouvernement pour résoudre, si possible, les graves et dangereux problèmes résultant de l'installation inacceptable d'importantes forces VC/NVN en territoire khmer.

Prochain article une fausse «Guerre Civile »

Chau Xeng Ua
Ancien Ministre